សាលាដំបូងខេត្តបន្ទាយមានជ័យ

តុលាការព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌលេខ ១១៧៤

ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

សាលក្រមលេខ ១៦(ច)/៨៦

ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈ

នៅសាលាដំបូងខេត្តបន្ទាយមានជ័យ

នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ដែលមានសមាសភាពដូចតទៅៈ

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

លោក ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ឋានៈព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈក្រឡាបញ្ជីសាលាដំបូងខេត្ត

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៧៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា ភេទប្រុស ថ្ងៃខែឆ្នាំកំណើត២០០៣ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ កើតនៅភូ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានភូមិ [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] វីរៈ "រ" ម្តាយឈ្មោះ [redacted] ឈូរ៉ាត់ "រ" ទោសពីមុនគ្មាន ជាអនីតិជន។ ឃុំខ្លួនថ្ងៃទី២៣-១០-២០២០។

ជាប់ចោទពីបទៈ លួច (ម៉ូតូ) ប្រព្រឹត្តនៅចំណុចខាងត្បូងផ្សាររាត្រីទឹកពុះ ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សៀន ភេទប្រុស អាយុ៣៥ឆ្នាំ អាសយដ្ឋាននៅភូមិមិត្តភាព សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

អង្គហេតុចោទប្រកាន់មានដូចតទៅ ៖ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង០២ និង៣០ នាទី នៅចំណុចខាងត្បូងផ្សាររាត្រីទឹកពុះ ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានឈ្មោះ វី ភេទប្រុស អាយុប្រហែល៣០ឆ្នាំ រស់នៅម្តុំវត្តគ្រាប ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានប្រើឲ្យឈ្មោះ [redacted] ចាន់ឡា

ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

ជំពូកទី

ភេទប្រុស អាយុ១៧ឆ្នាំ ទៅយកម៉ូតូមួយគ្រឿងម៉ាក ហុងដាឌ្រីម ពណ៌ខ្មៅ មានលេខតួម៉ាស៊ីន ៨៣៣៖ ៥៦២ ផលិតឆ្នាំ២០១៥ ពាក់ផ្លាកលេខបាត់ដំបង 1G-1575 ជារបស់ជនរងគ្រោះឈ្មោះ [redacted] សឿន ភេទប្រុស អាយុ៣៥ឆ្នាំ រួចឈ្មោះ [redacted] ចាន់ឡា បានបណ្តើរចេញមកក្រៅ ភ្លាមនោះក៏ត្រូវបានសន្តិសុខនៅក្បែរនោះឃើញហើយចាប់ខ្លួន និងបានប្រគល់ឲ្យសមត្ថកិច្ចកងរាជអាវុធហត្ថក្រុងប៉ោយប៉ែតតែម្តង ៖ ឈ្មោះ រី បានរត់គេចខ្លួនបាត់។ ចំណែកម៉ូតូប្រគល់ឲ្យម្ចាស់ដើមវិញហើយ។ ក្រោយមកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ ដីកាសន្និដ្ឋានស្ពាពរលេខ ១១៨៤ អយខ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៥២៣៧ ពស.ព្រស"ខ"/២០ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៥ ពស.ព្រជ"ក"/២០ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ។

## នាពេលសវនាការ

ក្រោយពីបាន ស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនជាប់ទាក់ទិនក្នុងសំណុំរឿង

ក្រោយពីបាន ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង

ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានកការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបាន ស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

## ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ សាលាដំបូងខេត្តបន្ទាយមានជ័យ យល់ឃើញថា

១. ជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា ភេទប្រុស កើតឆ្នាំ២០០៣ (អត្តសញ្ញាណខាងលើ) ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ បញ្ជូនមកជំនុំជម្រះពីបទ លួច (ម៉ូតូ) ប្រព្រឹត្តនៅចំណុចខាងត្បូងផ្សាររាត្រីទឹកពុះ ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា បញ្ជាក់ថា ខ្លួនអូសម៉ូតូគេមែន តែមិនបានចូលរួមលួចទេ គឺវាប្រើឲ្យអូសទៅ។ ថ្ងៃនោះទីម្តៃពីរ ម៉ោងដប់ពីរយប់ ខ្លួននៅផឹកជាមួយឈ្មោះ រី នៅផ្សាររាត្រី ហើយពេលឈប់ផឹកវាប្រើខ្លួនឲ្យយកម៉ូតូវាដែលជិះមកជាមួយគ្នា ហើយក៏មានអ្នកផ្សេងដែលខ្លួនមិនស្គាល់ឈ្មោះ ម៉ូតូមានសោរនិងផ្លាកលេខហើយជិះមកជាមួយគ្នា ហើយម៉ូតូមិនបានផ្ញើរនឹងកន្លែងផ្ញើរទេ ហើយពេលទុកគេអូសទុក។ តែពេលទៅយកវាឲ្យខ្លួនទៅយក តែមិនឲ្យសោរទេឲ្យបណ្តើរមកចាំខាងមុខ ហើយខ្លួនបានរង់ចាំប្រហែលជាដប់ទៅម្ភៃនាទីទើបគេមកចាប់ខ្លួន ពេលនោះខ្លួនស្រវឹងដែរ ខ្លួនទើបតែស្គាល់ឈ្មោះ រី ដែរ។ ពេលទៅផឹកជិះម៉ូតូ [illegible] មិនដឹងថាជាម៉ូតូតែមួយឬអត់ទេ ដឹង

[redacted]



Scanned with CamScanner

តែស្ទូន្យដប់ប្រាំដូចគ្នា គេប្រាប់ថាម៉ូតូនិងអត់ចាក់សោរកទេ ហើយអង្គុលម៉ូតូឲ្យខ្លួនរួចដើប គេថាគេទេ ទិញអីញ៉ាំថែម នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនដកហូតទូរស័ព្ទអិនចុចពិលមួយ។

៣. តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា បញ្ជាក់ថា កាលពីថ្ងទី២១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង២២យប់ ខ្លួនបានផឹកស៊ីជាមួយឈ្មោះ រី ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ រស់នៅភូមិវត្តត្រាច ភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានគ្នាចំនួន០៤ទៅ០៥នាក់ ខ្លួនស្គាល់តែឈ្មោះ រី និងឈ្មោះ តៀ ចំណែកអ្នកផ្សេងខ្លួនមិនស្គាល់ទេ មុនពេលផឹកស៊ីឈ្មោះ រី បានយកម៉ូតូម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០១៥ ពណ៌ខ្មៅ មកដែរ ប៉ុន្តែមិនដឹងកន្លែងទុកទេ។ ពួកខ្លួនផឹកស៊ីរហូតដល់ម៉ោង០១ជាងយប់ ឈានចូលដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ពេលនោះពួកខ្លួនបានឈប់ផឹក ឈ្មោះ រី បានប្រើឲ្យខ្លួនទៅយកម៉ូតូគេទុកនៅកន្លែងគៀនក្លឹបខាងត្បូងផ្សាររាត្រី ពេលនោះឈ្មោះ រី មិនបានឲ្យកូនសោរមកខ្លួនទេ កូនសោរម៉ូតូនោះនៅគេ ប៉ុន្តែគេបានចង្អុលប្រាប់ម៉ូតូនោះជារបស់គេ ហើយខ្លួនដើរបណ្តើរយកម៉ូតូពីកន្លែងទុកម៉ូតូនោះ ម៉ូតូនោះម៉ាកហុងដាឌ្រីម២០១៥ ពណ៌ខ្មៅ ពេលដែលឈ្មោះ រី បានប្រាប់ម៉ូតូខ្លួនហើយ ឈ្មោះ រី បានដើរទៅវិញ ខ្លួនក៏បានដើរទៅយកម៉ូតូនោះ ម៉ូតូនោះមិនបានចាក់សោរកទេ ខ្លួនអូសបណ្តើរម៉ូតូប្រហែលជាដប់ម៉ែត្រ ក៏បានអង្គុយចាំនៅលើម៉ូតូនោះប្រហែល១០នាទី មានគេមកនិយាយថាម៉ូតូនោះជាម៉ូតូរបស់គេ រួចគេបានចាប់ខ្លួនឲ្យទៅសមត្ថកិច្ចកងរាជអាវុធហត្ថក្រុងប៉ោយប៉ែតតែម្តង។ ចំណែកឈ្មោះ រី មិនដឹងថាទៅណាទេ ខ្លួនស្គាល់ឈ្មោះ រី ប្រហែលជាប្រាំ ទៅប្រាំមួយថ្ងៃហើយ ពេលដែលខ្លួនទៅលេងក្រុងប៉ោយប៉ែត ចំពោះម៉ូតូដែលខ្លួនយកទៅឲ្យគេនោះ សមត្ថកិច្ចបានប្រគល់ទៅឲ្យម្ចាស់ដើមវិញហើយកន្លងមកខ្លួនពុំធ្លាប់ធ្វើសកម្មភាពលួចម៉ូតូគេទេ ។

៤. តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សឿន បញ្ជាក់ថា កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង១៨ និង០០ ខ្លួនបានចតម៉ូតូហុងដាឌ្រីម ពណ៌ខ្មៅ មានលេខតួ លេខម៉ាស៊ីន ៨៣៣៦៥៦២ ផលិតឆ្នាំ២០១៥ ពាក់ផ្លាកលេខ បាត់ដំបង 1G-1575 នៅមុខកន្លែងធ្វើការរបស់ខ្លួន នៅខាងត្បូងផ្សារទឹកពុះ រហូតដល់ម៉ោង១២ ឈានចូលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ មេការរបស់ខ្លួនបានខ្ចីម៉ូតូទៅសម្រាកមុន ខ្លួនបានប្រគល់កូនសោរម៉ូតូ ហើយចេញមកយកម៉ូតូ ស្រាប់តែបាត់ម៉ូតូសន្តិសុខបានឃើញហើយស្រែកថាចាប់បានចោរ ស្រាប់តែខ្លួនទៅមើលឃើញម៉ូតូនោះជារបស់ខ្លួន។

៥. ជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា បានឆ្លើយថាពិតជាបានបណ្តើរ ឬ អូសម៉ូតូរបស់ជនរងគ្រោះ ចេញពីកន្លែងទុកមែន តែថា តាមការប្រើរបស់ឈ្មោះ រី និងគិតថា ជាម៉ូតូរបស់ឈ្មោះ រី ផ្ញើទៅវិញ ពុំមានភស្តុតាងណាមួយមកបញ្ជាក់នោះទេ សូម្បីឈ្មោះ រី ក៏មិនមានអត្តសញ្ញាណ ដែលអាចឱ្យតុលាការធ្វើចំណាត់ការនីតិវិធីនោះឡើយ និងត្រូវបានលើកលែងចោទប្រកាន់ដោយមូលហេតុគ្មានអត្តសញ្ញាណគ្រប់គ្រាន់ទៀតផង។

៦. ជាក់ស្តែងពេលចាប់ខ្លួន និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា គឺវត្ថុតាងជាម៉ូតូនៅនឹងដៃរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា ដែលឈ្មោះ [redacted] ចាន់ឡា បានយកម៉ូតូរបស់ជនរងគ្រោះ ចេញពីកន្លែងទុក ទៅកន្លែងមួយផ្សេងទៀត ដោយគ្មានជាប់សោរក ក្នុងគោលបំណងរង់ចាំគ្នា ដើម្បីយកម៉ូតូ ដែលអំពើនេះត្រូវបានផ្តន្ទាទោសដោយមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ។



[redacted]

៧. តាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ បានចែង ថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធខ្លួន{...}។

៨. ជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា គឺជានីតិជន ដែលមានប្រាជ្ញាស្មារតី និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលខុសចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។

៩. អំពើរបស់ជនជាប់ចោទបានប្រព្រឹត្តធ្វើឲ្យប៉ះពាល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។

១០. មានធាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា ភេទប្រុស កើតឆ្នាំ២០០៣ (អត្តសញ្ញាណខាងលើ) ពីបទ លួច (ម៉ូតូ) ប្រព្រឹត្តនៅភូមិអូរអណ្តូង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

១១. ជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួន នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០។

១២. ដើមបណ្តឹងទទួលបានម៉ូតូវិញ និងមិនបានចូលរួមក្នុងនីតិវិធីបន្តបន្ទាប់ដែលបញ្ជាក់បានថា ឈ្មោះ [redacted] សឿន មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបន្ត គប្បីតុលាការមិនយកមកពិចារណា។

១៣. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនាពេលសវនាការថា តាមរយៈរបាយការណ៍ និងកិច្ចស៊ើបសួរព្រមទាំងភស្តុតាងនានា ឃើញថាពិតជាមានអំពើលួចមែន ជនជាប់ចោទមានចេតនាយកទ្រព្យអ្នកដទៃ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ការបដិសេធគ្រាន់តែជាកាដោះសារប៉ុណ្ណោះ ស្នើសុំផ្តន្ទាទោសតាមច្បាប់ ដែលការសន្និដ្ឋានប្តឹងសុំនេះត្រឹមត្រូវ គប្បីយកមកពិចារណាសម្រេចអំពីពិរុទ្ធភាព និងទោស។

១៤. សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទនាពេលសវនាការថា តាមចម្លើយ ចាន់ឡា ពីដើមដល់សវនាការឃើញថាឆ្លើយតែមួយ កូនក្តីរបស់ខ្លួនអូសម៉ូតូគេមែនតែសំខាន់នៅអង្គុយរង់ចាំ តែបើមាត្រា ៣៥៣ ទាល់តែយករបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិនៅក្នុងសំណុំរឿងនេះ ចាន់ឡា គ្មានចេតនាទេ ដូច្នេះមិនគ្រប់អង្គហេតុបញ្ជាក់ថាមានចេតនាយកជាកម្មសិទ្ធិទេ មួយទៀតគាត់ជាអនីតិជន ណាមួយម្តាយឈឺធ្វើរើមិនកើត ហើយបើមានការកាត់ក្តីណាមួយនោះនឹងធ្វើឱ្យប៉ះពាល់ដល់គាត់ និងគ្រួសារគាត់យ៉ាងខ្លាំង ស្នើសុំពិចារណាលើកលែងទោស គប្បីយកមកពិចារណាសម្រេចពីពិរុទ្ធភាព។

១៥. សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទនាពេលសវនាការថា ដូចសហភាគីខ្លួនបញ្ជាក់អញ្ចឹង មានអង្គហេតុអូសម៉ូតូមែនតែពាក់ព័ន្ធនឹងចេតនា ដូចចម្លើយកូនក្តីខ្លួនបានបញ្ជាក់អញ្ចឹង ហើយមួយទៀតបើមានចេតនាយកម៉ូតូគេមែន មិនមែនអូសមកហើយអង្គុយរង់ចាំ និងឈរក្បែរកន្លែងកើតហេតុទេយកទៅលក់ហើយ ទោះបីគ្មានភស្តុតាងដោះបន្ទុកតែសក្ខីកម្មកាត់ និងចម្លើយគាត់ ស្នើសុំឲ្យរួចផុតបទចោទ គប្បីយកមកពិចារណាសម្រេចពីពិរុទ្ធភាព។

ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១

ចៅក្រម

[redacted]

១៦. សេចក្តីសន្និដ្ឋានតបរបស់តំណាងអយ្យការនាពេលសវនាការថា ការដកហូតនោះមិនមែន ទាល់តែយកជាកម្មសិទ្ធិទេ តែរឿងនេះជនជាប់ចោទបានអូសពីកន្លែងមួយទៅកន្លែងមួយ គឺគ្រប់គ្រាន់ហើយ ការង់ចាំគឺចាំគ្នាមកប៉ុណ្ណោះ គប្បីយកមកពិចារណាសម្រេចអំពីពិរុទ្ធភាព។

១៧. សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនាពេលសវនាការថា តាមមាត្រា ៣៥៣ ទាល់តែមានចេតនាទុច្ចរិត តែកូនក្តីខ្លួនមិនដឹងថាឈ្មោះ រី លួចគេទេបើគាត់ដឹងពីសកម្មភាពទើប ត្រឹមត្រូវតែពីថាគាត់មានចេតនាសុំសម្រេចតាមច្បាប់ គប្បីយកមកពិចារណាសម្រេចពីពិរុទ្ធភាព។

១៨. វត្ថុតាងដែលសមត្ថកិច្ចដកហូតបានពីឈ្មោះ [redacted] ចាន់ឡា ហើយបញ្ជូនមករក្សាទុកនៅ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ មានជាទូរស័ព្ទមួយគ្រឿង ដូចមានក្នុងកំណត់ហេតុទទួល វត្ថុតាងលេខ ៥៤៧ អយខ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយ មានជ័យ មិនពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស គប្បីប្រគល់ឱ្យម្ចាស់ដើមវិញ។

**ហេតុដូច្នេះ សាលាដំបូងខេត្តបន្ទាយមានជ័យ**

**វិនិច្ឆ័យសេចក្តី**

ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា

១-ផ្តន្ទាទោសលើជនជនជាប់ចោទឈ្មោះ [redacted] ចាន់ឡា ភេទប្រុស កើតឆ្នាំ២០០៣ ដាក់ពន្ធនាគារ កំណត់ ០៨(ប្រាំបី)ខែ ពីបទ លួច (ម៉ូតូ) ប្រព្រឹត្តនៅចំណុចខាងត្បូងផ្សាររាត្រី ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ បទល្មើស មានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

២-ប្រគល់ឱ្យម្ចាស់ដើមវិញ នូវទូរស័ព្ទមួយគ្រឿង មានកំណត់ហេតុទទួលវត្ថុតាងលេខ ៥៤៧ អយខ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ។ ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

.................................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៦កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

បន្ទាយមានជ័យ, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]